Whooping Cough (Pertussis) Notification
Type in name of school

ជូនចំពោះមាតាបិតា និងអាណាព្យាបាល ជាទីគោរពរាប់អាន៖

លិខិតនេះ ជូនដំណឹងលោកអ្នកថា កូនលោកអ្នកអាចត្រូវបានគេដាក់ឱ្យត្រូវចំជម្ងឺក្អកមាន់នៅសាលា។

ក្អកមាន់ ក៏ត្រូវបានគេហៅផងដែរថា ជម្ងឺក្អកមាន់ គឺជាការឆ្លងបាក់តេរីរាលដាលយ៉ាងខ្លាំង ដែលអាចឆ្លងតាមរយៈការទាក់ទង ជិតស្និទ្ធ នៅពេលមនុស្សមានជម្ងឺក្អក។ រោគសញ្ញានានា អាចបង្ហាញក្នុងរយៈពេល 5 ដល់ 21 ថ្ងៃ បន្ទាប់ពីការឆ្លងរោគ។ តាមធម្មតាវាចាប់ផ្តើមដូចគ្នាទៅនឹង ផ្តាសាយធម្មតា (ឧទាហរណ៍ កណ្តាស់ ហៀរសំបោរ ជាដើម) ដោយមានក្អកកាន់តែ អាក្រក់ទៅៗក្នុងរយៈពេល ពីមួយទៅពីរសប្តាហ៍។ មនុស្សដែលមានក្អកមាន់ អាចមានក្អកបាត់បង់ស្មារតីខ្លីៗ ដែលក្នុងនោះ ពួកគេមិនអាចដកដង្ហើមរបស់ពួកគេនៅចន្លោះការក្អក។ អ្នកខ្លះទៀត អាចក្អកជាឈប់ៗខ្លាំងៗ (“ដំណើរក្អកខ្លាំងហើយយូរ”) និងក្អួត ឬមានអារម្មណ៍ ដូចជាពួកគេកំពុងតែស្លាក់ឬឈ្លក់របស់អ្វីមួយ។ តាមធម្មតា ពួកគេពុំមានគ្រុនក្តៅខ្លួន ពីការក្អកមាន់ឡើយ។

កុមារក្មេងៗ ដែលមិនបានបំពេញតាមដំណាក់កាលការចាក់ថ្នាំបង្ការ DTaP របស់ពួកគេ គឺស្ថិតនៅកម្រិត ហានិភ័យថ្ងៃណាមួយ ចំពោះភាពស្មុគស្មាញធ្ងន់ធ្ងរពីជម្ងឺក្អកមាន់។ ថ្នាំបង្ការជម្ងឺក្អកមាន់ (DTaP) ត្រូវបានផ្តល់អនុសាសន៍ទៅតាមអាយុ 2, 4, 6, និង 15-18 ខែ។ កម្រិតថ្នាំ DTaP ចាក់បង្ការរោគបបន្ថែម ត្រូវបានចាក់ថ្នាំកុមារៗមុនការចូលរៀនសាលាមត្តេយ្យ នៅអាយុ 4-6 ឆ្នាំ; កម្រិតថ្នាំ DTaP ចាក់បង្ការរោគបបន្ថែម ត្រូវបានផ្តល់អនុសាសន៍ចាក់ថ្នាំនៅសាលាមធ្យមសិក្សា នៅអាយុ 11-12 ឆ្នាំ។ យើងខ្ញុំ ជម្រុញលើកទឹក ចិត្តលោកអ្នក ដើម្បីធ្វើឱ្យប្រាកដថា កូនលោកអ្នក បានទទួលកម្រិតថ្នាំ DTaP ដែលបានផ្តល់អនុសាសន៍ ទាំងអស់ តាមរយៈការពិនិត្យមើលកំណត់ត្រាស្តីពីការចាក់ថ្នាំបង្ការឬការធ្វើឱ្យស៊ាំនឹងជម្ងឺ ឬការទាក់ទងអ្នកផ្តល់សេវាកម្មថែទាំ សុខភាពកូនលោកអ្នក។

ជាទូទៅថ្នាំចាក់បង្ការរោគក្អកមាន់ មានប្រសិទ្ធភាពយ៉ាងខ្លាំង ទាំងនៅក្នុងការការពារជម្ងឺឆ្លង ឬការកាត់បន្ថយកម្រិតធ្ងន់ស្រាល របស់ពួកគេភ្លាមៗ បន្ទាប់ពីការទទួលបានតាមដំណាក់ កាលនៃថ្នាំចាក់បង្ការរោគ ឬកម្រិតថ្នាំចាក់បង្ការរោគបបន្ថែម។ ប៉ុន្តែ ភាពស៊ាំនឹងរោគក្អកមាន់ ធ្វើឱ្យបាត់បន្តិចម្តងៗយ៉ាងឆាប់រហ័សតាមពេលវេលាកន្លងទៅ បើទោះជាកុមារៗដែលបានចាក់ថ្នាំ បង្ការរោគពេញលេញក៏ដោយ ក៏អាចមានជម្ងឺក្អកមាន់ផងដែរ។

កម្រិតថ្នាំបង្ការរោគបបន្ថែម (Tdap) ត្រូវបានគេផ្តល់អនុសាសន៍ចំពោះមនុស្សពេញវ័យ ជាពិសេសស្ត្រីមានគភ៌ (ចាក់បង្ការ ជារៀងរាល់មានគភ៌) និងអ្នកមើលថែរក្សាទារកតូចៗ។ បើលោកអ្នក ឬកូនធំៗរបស់អ្នក មិនបានចាក់ថ្នាំបង្ការ Tdap នោះ គេបាន ផ្តល់អនុសាសន៍លោកអ្នកថា លោកអ្នកត្រូវឱ្យពួកគេចាក់ថ្នាំបង្ការ។ ការចាក់ថ្នាំបង្ការរោគ Tdap អាចមាននៅតាមការិយាល័យ វេជ្ជបណ្ឌិតជាច្រើន, ជាទូទៅឱសថស្ថាន និងនាយកដ្ឋានសុខាភិបាលមូលដ្ឋានខ្លះ ដែលត្រូវបានចេញថ្លៃពីផែនការធានារ៉ាប់រង ភាគច្រើន។

បើកូនអ្នកលោកមានរោគសញ្ញា ហើយកំពុងតែក្អកនោះ សូមទាក់ទងមកវេជ្ជបណ្ឌិតរបស់លោកអ្នក។ ប្រាប់វេជ្ជបណ្ឌិតថា ករណី ក្អកមាន់ដែលបានបញ្ជាក់ ត្រូវបានរាយការណ៍នៅសាលាកូនរបស់លោកអ្នក។ ការធ្វើតេស្តត្រឹមត្រូវបំផុត ចំពោះការធ្វើរោគវិនិច្ឆ័យ ក្អកមាន់ ត្រូវបានគេប្រមូលដោយប្រើ សំឡីយកសំណាកតាមច្រមុះ។ **បើលោកអ្នកត្រូវបានពិនិត្យដោយវេជ្ជបណ្ឌិត ហើយក្អកមាន់ បានត្រូវធ្វើរោគវិនិច្ឆ័យនោះ សូមរក្សាកូនលោកអ្នកឱ្យនៅផ្ទះ រហូតដល់លោកអ្នកបានបំពេញរយៈពេល 5 ថ្ងៃ នៃការព្យាបាល ដោយប្រើថ្នាំអង់ទីប៊ីយ៉ូទិកដែលបានចេញវេជ្ជបញ្ជា។**

ក្រសួងសុខាភិបាលមូលដ្ឋាននឹងបន្តស៊ើបអង្កេតស្ថានភាពនេះ។ បើលោកអ្នក ឬវេជ្ជបណ្ឌិតលោកអ្នក មានសំណួរណាមួយ សូមប្រើព័ត៌មានទំនាក់ទំនងខាងក្រោម។

ដោយក្តីគោរពខ្ពង់ខ្ពស់,

Type in signature and contact information here:

Name, Principal
Name of School Contact: phone number

Name, County Health Officer
Health Department Name: phone number